00988559

E309

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 05 / 2014
ម៉ោង (Time/Heure): 10:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

ផ្ញើជូន៖ **ភាគីទាំងអស់នៅក្នុងសំណុំរឿង ០០២**

ពី៖ **ចៅក្រម និល ណុន**
**ប្រធាន អង្គជំនុំជម្រះសាលាដំបូង**

ចម្លងជូន៖ **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

កម្មវត្ថុ៖ **សេចក្តីសម្រេចលើសំណើសុំឱ្យដាក់ទណ្ឌកម្មចំពោះក្រុមមេធាវីការពារក្តី ខៀវ សំផន**

១. អង្គជំនុំជម្រះបានទទួលសំណើចំនួនពីរពីការិយាល័យសហព្រះរាជអាជ្ញាដែលបានស្នើសុំអង្គជំនុំជម្រះដាក់ទណ្ឌកម្មដល់សមាជិកនៃក្រុមមេធាវីការពារក្តីឱ្យជនជាប់ចោទ ខៀវ សំផន[1]។

២. សំណើទីមួយបានធ្វើឡើងនៅក្នុងអំឡុងពេលសួរដេញដោលសាក្សីឈ្មោះ សូ សុជាតិ នៅក្នុងសវនាការ។ លោក គង់ សំអុន ដែលជាមេធាវីការពារក្តីឱ្យជនជាប់ចោទ ខៀវ សំផន បានជំទាស់ទៅនឹងសំណួរមួយដែលបានចោទសួរសាក្សីរូបនេះពីសំណាក់លោក Keith RAYNOR មកពីការិយាល័យសហព្រះរាជអាជ្ញា[2]។ ទោះបីជាសក្ខីកម្មពីមុនរបស់សាក្សី

---

[1] ប្រតិចារិក ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៣៦-៣៧។ ប្រតិចារិក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៥៦-៥៧។

[2] ប្រតិចារិក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៧៨។

00988560

E309

ត្រូវបានអានឲ្យគាត់ស្តាប់ជាភាសាអង់គ្លេស និងជាភាសាខ្មែរមុនពេលតាំងសំណួរក៏ដោយ[3] ក៏លោក សំអុន បានបញ្ជាក់ថា ការអានឡើងវិញរបស់លោក RAYNOR គឺមិនត្រឹមត្រូវតាមខ្លឹមសារពិតនៃសក្ខីកម្មរបស់សាក្សីទេ ហើយបានបន្តបកស្រាយឡើងវិញលើប្រយោគមួយផ្នែកតូចនៅក្នុងសក្ខីកម្មពីមុនរបស់សាក្សីរូបនេះ[4]។ លោក RAYNOR បានចាត់ទុកទង្វើនេះថាជាការប៉ុនប៉ងជ្រៀតជ្រែកលើសាក្សី ហើយបានស្នើសុំដល់អង្គជំនុំជម្រះឲ្យធ្វើការព្រមាន និងដាក់ទណ្ឌកម្មមេធាវីជាតិរូបនេះ[5]។

៣. បន្ទាប់ពីអង្គជំនុំជម្រះបានពិនិត្យមើលប្រតិចារឹកជាភាសាអង់គ្លេស និងជាភាសាខ្មែរនៃការឆ្លើយឆ្លងគ្នានេះ ឃើញថា ពុំមានអ្វីច្បាស់លាស់ដែលបង្ហាញ ថាតើមេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន ពិតជាមានចេតនាជ្រៀតជ្រែកលើសាក្សីរូបនេះ ឬ យ៉ាងណានោះទេ។ ទោះបីជាសំណៅបកប្រែជាភាសាអង់គ្លេសនៃការជំទាស់របស់លោក សំអុន បង្ហាញថាគាត់បានជូនដំណឹងដល់អង្គជំនុំជម្រះ ដោយមានវត្តមានរបស់សាក្សី អំពីអ្វីដែលគាត់បានគិតថាសាក្សីចង់និយាយក៏ដោយ ក៏សំណៅដើមជាភាសាខ្មែរនៃប្រតិចារឹកនោះមានន័យមិនច្បាស់លាស់[6] ដែលអាចកំណត់ថា លោក សំអុន មានចេតនាណែនាំសាក្សីឡើយ។ ដោយផ្អែកលើបទដ្ឋានដែលបានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល[7] និងដោយពិចារណាលើភាព

---

[3]ប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៧៥-៣៧។

[4]ប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៧៨។

[5]ប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៧៨។ ប្រតិចារឹក ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៣៦-៣៧។

[6]លោក គង់ សំអុន បានបញ្ជាក់ថា៖ “អញ្ចឹង ការអាននេះវាអាចធ្វើឲ្យមានបញ្ហាច្រឡំដែរ។ គឺនៅពេលដែលលោក ខៀវ សំផន មានជួយហ្នឹង គឺអ្នកស្រី ជាសាក្សីចង់បញ្ជាក់ថា កូនគាត់បានជិត ១ ខែ។ ដូច្នេះ វាអត់មានអីជាពិបាកយល់ទេ”។ ប្រតិចារិក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៧៨(ភាសាអង់គ្លេស)។ អង្គជំនុំជម្រះ យល់ថា ឃ្លាថា “គាត់ចង់បញ្ជាក់” អាចបកប្រែថា“គាត់សង្កត់ធ្ងន់/បញ្ជាក់/សង្កត់ន័យ)”។ ភាពខុសគ្នាបន្តិចបន្តួចផ្នែកភាសា អាចជាភាពខុសគ្នារវាងការប្រាប់សាក្សីរូបនោះអំពីអ្វីដែលត្រូវនិយាយ ជាមួយនឹងការដែលគ្រាន់តែនិយាយឡើងវិញអំពីសក្ខីកម្មពេលមុនរបស់សាក្សីរូបនោះប៉ុណ្ណោះ។

[7] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ខ្លួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យចាត់ការជាបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឯកសារ E176/2/1/4 ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ កថាខណ្ឌ ៤៩ (គ្មានមូលដ្ឋានដែលត្រូវផ្តួចផ្តើមការស៊ើបអង្កេតតាមវិធាន ៣៥ ឡើយ ក្នុងករណីដែលអង្គជំនុំជម្រះតុលាការកំពូលមិនជឿជាក់លើភស្តុតាងអំពីចេតនាជាក់លាក់ និងក្នុងករណីដែលអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា “ពុំមានភាពទំនងទាល់តែសោះដែលថា ការបង្ហាញភស្តុតាងនៃចេតនាជាក់លាក់បែបនេះដូចជាការទទួលស្គាល់នូវសេចក្តីថ្លែងការណ៍របស់

មិនច្បាស់លាស់នៃពាក្យពេចន៍របស់មេធាវីនៅក្នុងអំឡុងពេលសវនាការ អង្គជំនុំជម្រះមិនអាចដាក់ទណ្ឌកម្មមេធាវីចំពោះទង្វើនេះបានឡើយ។ ទោះបីជាយ៉ាងណា អង្គជំនុំជម្រះសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការអនុញ្ញាតឱ្យមានការសួរដេញដោលសាក្សី និងការពិនិត្យភ័ស្តុតាង។ អង្គជំនុំជម្រះស្នើឱ្យមេធាវីទាំងអស់មានការប្រយ័ត្នប្រយែងនៅក្នុងសវនាការនាពេលអនាគត ដោយមិនត្រូវផ្តល់ការណែនាំណាមួយដល់សាក្សីដែលកំពុងត្រូវបានចោទសួរដោយភាគីម្ខាងទៀតឡើយ។

៤. សំណើទីពីររបស់សហព្រះរាជអាជ្ញា គឺធ្វើឡើងបន្ទាប់ពីមានការចុះផ្សាយក្នុងសារព័ត៌មានចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ នូវអត្ថបទជាភាសាអង់គ្លេសដែលសរសេរដោយក្រុមមេធាវីការពារក្តីឱ្យជនជាប់ចោទ ខៀវ សំផន គឺអ្នកស្រី Anta GUISSÉ លោក Arthur VERCKEN និងលោក គង់ សំអុន[8]។ អត្ថបទនេះ បានរៀបរាប់នូវកំហុសឆ្គងផ្នែកនីតិវិធីយ៉ាងច្រើនដែលមេធាវីយល់ថាបានកើតឡើងនៅក្នុងការជំនុំជម្រះក្តី ហើយក៏បានរិះគន់សេចក្តីសម្រេចនានារបស់ចៅក្រមនៅ អ.វ.ត.ក ផងដែរ។ ជាពិសេស អត្ថបទនេះសំដៅលើការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង ០០២/០១ ដោយបានហៅការជំនុំជម្រះនេះថាជា "ការរត់ប្រណាំងប្រជែងជាមួយនឹងសេចក្តីស្លាប់" និងថាជា"ការជំនុំជម្រះក្តីបែបឆាកល្ខោន"។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ពាក្យពេចន៍នៃការចោទប្រកាន់នៅក្នុងអត្ថបទនេះគឺមិនត្រឹមត្រូវទាល់តែសោះដែលមានន័យស្មើនឹងការប៉ុនប៉ងយ៉ាងច្បាស់ក្នុងការជ្រៀតជ្រែកចូលទៅក្នុង

---

ខ្លួន នឹងត្រូវទទួលបានតាមរយៈការផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ"(បន្ថែមការសង្កត់ន័យ)។ សេចក្តីសម្រេចលើ "បណ្តឹងសាទុក្ខភ្លាមរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់តាមវិធាន ៣៥" ឯកសារ E189/3/1/8 ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ២៧ (អង្គជំនុំជម្រះសាលាដំបូង អាចចេញការព្រមានទៅមេធាវី តាមវិធានផ្ទៃក្នុង ៣៨ ចំពោះតែ("ការប្រព្រឹត្តិណាដែលមានលក្ខណៈជាក់ស្តែងដែលនាំទៅរកការកំណត់<u>ច្បាស់លាស់</u>ថាជា [ការប្រព្រឹត្តិខុស]។ ក្នុងករណីដែលអាចនៅមានមន្ទិលនោះ នីតិវិធីកាន់តែប្រុងប្រយ័ត្នគួរយកមកអនុវត្ត"(បន្ថែមការសង្កត់ន័យ)។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ឯកសារE116/1/7 ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២៣ និង ៣៧ (ការព្រមានក្រុមមេធាវីការពារក្តី កុំឱ្យលាតត្រដាងចេញផ្សាយព័ត៌មានសម្ងាត់ និងសម្ងាត់បំផុតដោយគ្មានការអនុញ្ញាតជាបន្តទៀតក្នុងករណីដែលមេធាវីការពារក្តី បានសារភាពថាខ្លួនបានចែកចាយព័ត៌មានសម្ងាត់ទៅឱ្យសមាជិកផ្សេងៗនៃសារព័ត៌មានក្នុងស្រុក និងអន្តរជាតិ)។

[8] *ខៀវ សំផន ត្រូវបានបង្ខំឱ្យនៅឱ្យស្ងៀម* កាសែត ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣។

00988562



កិច្ចការរដ្ឋបាលតុលាការ និងជាការរំលោភបំពានក្រមសីលធម៌វិជ្ជាជីវៈដែលជាលក្ខខណ្ឌតម្រូវសម្រាប់មេធាវី[9]។

៥. អង្គជំនុំជម្រះកត់សម្គាល់ថា ការអះអាងជាច្រើនដែលបានលើកឡើងនៅក្នុងអត្ថបទសារព័ត៌មាននេះ គឺមានបញ្ចូលនៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្ដីឱ្យជនជាប់ចោទ ខៀវ សំផន នៅក្នុងសំណុំរឿង ០០២/០១[10] បើទោះបីជាប្រើភាសាមិនសូវអុជអាលក្ដី។ សារណាទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីនឹងត្រូវដោះស្រាយនៅក្នុងសាលក្រមនៃសំណុំរឿង ០០២/០១។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា វាជាការមិនសមស្របទេក្នុងការបង្ហាញការយល់ឃើញរបស់អង្គជំនុំជម្រះនៅពេលនេះ ថាតើអត្ថបទខាងលើបង្ហាញខុសការពិត ឬយ៉ាងណានៅក្នុងករណីនេះ ហើយអង្គជំនុំជម្រះបដិសេធមិនដាក់ទណ្ឌកម្មណាមួយទៅលើមេធាវីការពារក្ដី ខៀវ សំផន ឡើយ។

៦. អង្គជំនុំជម្រះរំឭកភាគីទាំងអស់ថា វេទិកាដ៏សមស្រប ត្រឹមត្រូវសម្រាប់ការជំទាស់តវ៉ានៅក្នុងសំណុំរឿង ០០២ គឺនៅក្នុងសាលសវនាការ និងតាមរយៈសារណានានាដាក់ជូនទៅអង្គជំនុំជម្រះនៃ អ.វ.ត.ក ដែលមានសមត្ថកិច្ចដោះស្រាយការតវ៉ាទាំងនោះ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការប្រើប្រាស់ភាសាមិនសមរម្យពីសំណាក់ក្រុមមេធាវីការពារក្ដីខាងលើ គឺជាការគួរឱ្យសោកស្ដាយ។ លើសពីនេះទៀត ការបង្ហាញនូវអង្គហេតុមិនពិតជូនអង្គជំនុំជម្រះ ឬសាធារណជន គឺជាបញ្ហាមួយធ្ងន់ធ្ងរ ហើយប្រសិនបើមានភស្ដុតាងបញ្ជាក់ថា ពិតជាបានធ្វើដូច្នេះមែននោះ អាចនាំឱ្យមានការដាក់ទណ្ឌកម្មមេធាវីពាក់ព័ន្ធ។

---

[9] ប្រតិចារឹក ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៤៨។

[10] ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៣ (សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ខៀវ សំផន) ទំព័រ ៣២-៣៣។ *សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល* [របស់ខៀវ សំផន] ទំព័រ ៤-៨។